Legal Aid Foundation of Los Angeles

# សំណុំឯកសារដែលយើងខ្ញុំកាន់កាប់

## បញ្ហាទីលំនៅ:

កំពុងតែធ្វើការរៀបចំជួយបុគ្គលណា ដែលបានត្រូវជាប់ឃុំឃាំងដោយខុសច្បាប់ និង ជួយតំណាងអតិថិជននៅក្នុងតុលាការទៀតផង ។ យើងខ្ញុំនឹងជួយដាក់ពាក្យបណ្តឹងក្នុងការជួសជុលផ្ទះ ជួយបញ្ឈប់ការតម្លើងថ្លៃផ្ទះអាគារ ដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ ការផ្តាច់អគ្គិសនី(ភ្លើង) និងទូរស័ព្ទ និង ការជួយសុំនិងដំណោះស្រាយអំពីបញ្ហាផ្ទះរដ្ឋ ។ យើងនឹងផ្តល់ជូននូវឯកសារកត់សំគាល់ចំនួន 3/30ថ្ងៃ មុនលោកអ្នកនឹងទទួលបានការជួសជុលឲ្យបានសំរេច ។

## ប្រាក់ជំនួយពីរដ្ឋាភិបាល:

យើងខ្ញុំជួយលោកអ្នកដូចជា: ខាល់ជីក, ប្រាក់ពិការ, មេឌីខាល់, មេឌីឃែរ, ហ្វូតស្តែម, សុំប្រាក់មើលអ្នកឈឺនៅផ្ទះ, ប្រាក់វែលហ្វែរ, ការថែទាំសុខភាព, ប្រាក់ទាហានចូលនិវត្តន៍, និង ប្រាក់ជំនួយទូទៅ ។

## វឌ្ឍនភាពសេដ្ឋកិច្ចនៃសហគមន៍:

យើងខ្ញុំជួយរៀបចំជាក្រុមសាជីវកម្ម ជួយរក្សាសិទ្ធិរបស់ក្រុមអង្គការឥតយកកម្រៃ ជួយផ្តួចផ្តើមក្នុងការផ្សងនូវមុខជំនួញ ជួយក្នុងការតាំងលំនៅសំរាប់គ្រួសារដែលមានសមាជិកច្រើន ការផ្តួចផ្តើមខាងពាណិជ្ជកម្ម និង ជួយលោកអ្នកអាចទិញផ្ទះបានផងដែរ ។

## ច្បាប់ការងារ:

យើងខ្ញុំជួយទាមទារជាថ័បង់ផ្នែកខាងប្រាក់ឈ្នួល និង ការបដិសេធនៃការសុំប្រាក់ពេលគ្មានការធ្វើ ។ យើងខ្ញុំជួយបុគ្គលិកទាំងឡាយណា ដែលត្រូវបានដេញចោលដោយខុសច្បាប់ទៀតផង ។

## ពាក្យបណ្តឹងនៃជនរងគ្រោះពីបទឧក្រិដ្ឋកម្ម:

យើងខ្ញុំជួយប្រជាជនដែលរស់នៅក្នុងទីក្រុងអិល អេ ដើម្បីដាក់ពាក្យតវ៉ាទៅក្នុងក្រសួងជួយជនរងគ្រោះពីឧក្រិដ្ឋកម្ម (Victims of Violent Crime Fund) ។

## ច្បាប់គ្រួសារ:

មូលនិធិជំនួយផ្លូវច្បាប់នៃទីក្រុងអិល-អេ ជួយផ្តល់និវាទ និង ការបង្ហាញណែនាំខ្លះៗចំពោះករណីយ៍ ដែលទាក់ទងនឹងសិទ្ធិនៃការទៅសួរសុខទុក្ខកូន (ដែលត្រូវបានគេដកយកទៅចិញ្ចឹម) និងប្រាក់ជួយចិញ្ចឹមកូន ហើយនិងអំពើហឹង្សានៅក្នុងផ្ទះ ។ សូមពិនិត្យនៅទំព័រម្ខាងទៀតដើម្បីស្វែងរកពេលវេលា និង ទីកន្លែង ។

## ច្បាប់អន្តោប្រវេស្តន៍:

យើងខ្ញុំជួយតំណាងឲ្យបងប្អូនទាំងឡាយណា ដែលត្រូវបានបណ្តេញចេញពីប្រទេសដោយសារច្បាប់ ហើយដែលនៅមានសិទ្ធិការពារខ្លួននៅឡើយ ។ ជួយជនអន្តោប្រវេសន៍ ដែលត្រូវបានទទួលរងគ្រោះពីអំពើហឹង្សាពីគ្រួសារឲ្យក្លាយទៅជាជនអាមេរិកាំងដ៏ពេញច្បាប់ ។

## ច្បាប់ជួញដូរ:

យើងខ្ញុំទទួលកាន់កាប់សំណុំរឿងទាក់ទងនឹងការក្លែងបន្លំ កុងត្រា ការធានារ៉ាប់រង ការខ្ចីប្រាក់ ការយល់ព្រមបណ្តាក់ខែ ការជួញដូរមិនត្រឹមត្រូវ ការប្រកាន់ពូជសាសន៍ក្នុងការខ្ចីប្រាក់ពីធនាគារ ការរំខានក្នុងការទាមទារបំណុល ការដកហូតទ្រព្យសម្បត្តិ និង ការកាត់ប្រាក់ខែមុនសេចក្តីសំរេចរបស់តុលាការ ។
*បើចង់បានដំបូន្មានជារៀងរាល់ខែក្នុងការបំបាត់បំណុលនៃការជំពាក់ សូមទូរស័ព្ទទៅលេខ: (213) 640-3964* ។

# សំណុំឯកសារដែលយើងខ្ញុំកាន់កាប់

យើងខ្ញុំអាចជួយលោកអ្នកផងដែរ កាលណាគេឯកហូតផ្ទះ និង ការខ្ចីប្រាក់សំរាប់ជួសជុលផ្ទះ, ការខ្ចីប្រាក់ចំណេញនៃតំលៃផ្ទះ, ការធានាជាទ្រព្យសម្បត្តិ ឬ ប្រាក់កាស់ នៅក្នុង តុលាការ, ការធានាដាក់រថយន្ត ឬក៏ ប្រភេទនៃការខ្ចី ប្រាក់ក្នុងការធានាដាក់ផ្ទះសង, ការធ្វេសប្រហែសក្នុងការជួសជុល តែងលំអផ្ទះ និង បញ្ហាច្បាប់ ដែលទាក់ទងនឹងការទិញលក់ផ្ទះរបស់លោកអ្នក ។

**Legal Aid Foundation**
**of Los Angeles**
គឺជាការិយាល័យច្បាប់មិនយកកំរៃ
ដែលជួយផ្តល់នូវជំនួយខាងផ្លូវ
ច្បាប់ស៊ីវិលចំពោះ អតិថិជនណា
ដែលមានប្រាក់ចំណូលតិច និង រស់
នៅក្នុងខណ្ឌ ឡូស អង់ចឺលែស

## តើនរណាមានសិទ្ធិអាចទទួលបាន:

យើងខ្ញុំទទួលនូវការអនុញ្ញាតិសំរាប់ជួយតែនរណា ដែលមានប្រាក់ចំណូលក្រោមកំណត់នៃរដ្ឋាភិបាលកំរិត និង រស់នៅក្នុងតំបន់ដែលមានជួយកិច្ចបំរើនេះ ។ លោកអ្នកចាំបាច់ប្រាប់នូវប្រាក់ចំណូល និង ទ្រព្យសម្បត្តិដែលមាន ។ លើសពីនេះទៀត គេនឹងសួរអំពីលេខស៊ីបកូដ (zip code) ចំនួនសមាជិកក្នុងគ្រួសារ អាយុ សញ្ជាតិ និង ការចូលសញ្ជាតិ ឬក៏លក្ខណៈជាជនអន្តោប្រវេសន៍ ។ គ្រប់ពត៌មានដែលលោកអ្នកបានផ្តល់មកយើងខ្ញុំគឺត្រូវបានរក្សាទុកជាការសម្ងាត់ និង មិនចែកចាយទៅឲ្យបុគ្គលណាផ្សេងផ្តាស់ឡើយ លើកលែងតែមានការអនុញ្ញាត្តិអំពីលោកអ្នកជាមុនសិន ។

## សំណុំឯកសារដែលយើងមិនទទួលបំរើ:

យើងខ្ញុំមិនទទួលសំណុំរឿងខាងបទឧក្រិដ្ឋ ឬ ឯកសារមួយណា ដែលផ្តល់កំរៃមកយើងខ្ញុំទេ ។

## តើធ្វើដូចម្តេចនឹងស្នើសុំការបំរើនេះ?

លោកអ្នកចាំបាច់ទូរស័ព្ទទៅកាន់ការិយាល័យ (Client Intake Number) ដែលមានលេខនៅទំព័រម្ខាងទៀតស្រាប់ ។ លោកអ្នកនឹងត្រូវបានណែនាំនូវការបំរើរបស់យើងយ៉ាងក្បោះក្បាយ និង មធ្យោបាយផ្សេងៗទៀត ដែលលោកអ្នកអាចធ្វើការជ្រើសរើសបាន ។ សូមមេត្តាស្តាប់សំលេងពីទូរស័ព្ទនេះឲ្យដោយប្រុងប្រយ័ត្ន ដើម្បីលោកអ្នកអាចទទួលការតភ្ជាប់នឹងអ្នកដឹងបញ្ហារបស់អ្នក ។ លោកអ្នកអាចស្តាប់សំលេងនេះសាឡើងវិញបាន ។

All walk-ins are welcome at
លោកអ្នកអាចមកជួបនឹងបុគ្គលិកខ្មែរដោយមិនបាច់មានការណាត់ជួបជាមុន នៅអាស័យដ្ឋានដូចខាងក្រោមនេះ
Every Tuesday
10 am –5 pm at
Cambodian Association of America
2501 Atlantic Ave.
Long Beach, CA
(562) 304-2523

យើងខ្ញុំមានបុគ្គលិកខ្មែរបំរើជូនលោកអ្នកនៅរៀងរាល់ថ្ងៃអង្គារ នៃអាទិត្យទី១ និង ទី៣ ពីម៉ោង ៩:០០ ព្រឹក ដល់ ម៉ោង ១២ ថ្ងៃត្រង់

Khmer Hot Line:(562) 304-2523 (Every Monday and Wednesday – from 9:00 am to 12 Noon)
*ទូរស័ព្ទជាភាសាខ្មែរ:* (562) 304-2523 *(ថ្ងៃច័ន្ទ និង ថ្ងៃពុធ ពីម៉ោង ៩:០០ ព្រឹក ដល់ ម៉ោង ១២ ថ្ងៃត្រង់)*